សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS
ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ ប្រអប់សំបុត្រ ៤៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ ទូរសារ: (+៨៥៥) ២៣ ៧២៧ ១០២/២១៧ ៦២៦ អ៊ីមែល: contact@licadho-cambodia.org

# ការវិភាគរបស់អង្គការ លីកាដូ អំពី
# សេចក្តីព្រាងច្បាប់ថ្មី ដែលបង្ហាញពី វប្បធម៌នៃការគ្រប់គ្រង

*ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៥*

សេចក្តីព្រាងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល (LANGO) ដែលទទួលបាននៅក្នុងខែមិថុនា ឆ្នាំ ២០១៥ នេះ នឹងតម្រូវឲ្យមានការចុះបញ្ជី ចំពោះសមាគម និង អង្គការមិនមែនរដ្ឋាភិបាល (NGOs) ក្នុងស្រុក (ជាតិ) និងអន្តរជាតិទាំងអស់ ហើយចាត់ទុកថាសកម្មភាពទាំងអស់របស់អង្គការណាដែលមិនបានចុះបញ្ជីសមាជិកភាពថាជាបទព្រហ្មទណ្ឌ។ ការតម្រូវឲ្យចុះបញ្ជីនេះ ហាក់បីដូចជា ត្រូវអនុវត្តទៅលើគ្រប់អង្គការទាំងអស់ ចាប់តាំងពីក្រុមមូលដ្ឋាន និងអង្គការសហគមន៍មូលដ្ឋានរហូតដល់អង្គការអន្តរជាតិសំខាន់ៗទៀតផង។ ការតម្រូវឲ្យចុះបញ្ជីនេះដែរ អាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ជាពិសេសលើសេរីភាពនៃការបង្កើតសមាគមនៃក្រុមមូលដ្ឋាន និងអង្គការសហគមន៍មូលដ្ឋាននានា។

ក្រសួងមហាផ្ទៃ នឹងមានឆន្ទានុសិទ្ធិពេញទីលើការយល់ព្រមចំពោះការចុះបញ្ជី ហើយលក្ខខណ្ឌនៃច្បាប់នេះ អាចអនុញ្ញាតឱ្យមានការបដិសេធពាក្យសុំចុះបញ្ជី ដោយសារហេតុផលនយោបាយ។

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិ និងសមាគមអន្តរជាតិទាំងអស់ ពេលបានចុះបញ្ជីរួចហើយ នឹងត្រូវមានកាតព្វកិច្ចរក្សាអព្យាក្រឹតភាពនយោបាយ ដែលមាននិយមន័យក្នុងច្បាប់នេះយ៉ាងស្រពិចស្រពិល។ រាជរដ្ឋាភិបាល នឹងអាចលុបឈ្មោះអង្គការណាមួយចេញពីបញ្ជីបាន ចំពោះការធ្វើរបាយការណ៍ស្របច្បាប់ ឬការរិះគន់ត្រឹមត្រូវ ផ្អែកលើមូលដ្ឋានទាំងនេះ។ រាជរដ្ឋាភិបាលមានសិទ្ធិយ៉ាងខ្លាំងក្នុងការចាត់វិធានដាក់ទណ្ឌកម្មមកលើសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ហើយរាជរដ្ឋាភិបាលនឹងមានអំណាចសម្រេចចិត្ត ក្នុងការលុបឈ្មោះក្រុមសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលទាំងនោះចេញពីបញ្ជី ការពិន័យហួសហេតុ និងការដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌមកលើរូបវន្តបុគ្គលនានា។ ច្បាប់នេះក៏នឹងអនុញ្ញាតឱ្យរាជរដ្ឋាភិបាលដាក់នៅក្នុងបញ្ជីខ្មៅនូវឈ្មោះមេដឹកនាំនានានៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីម្តងហើយ ដើម្បីហាមឃាត់បុគ្គលទាំងនោះមិនអោយបង្កើតអង្គការថ្មីមួយទៀត។ ច្បាប់នេះក៏បានផ្តល់អំណាចទៅដល់រាជរដ្ឋាភិបាលក្នុងការបញ្ចប់អនុស្សរណៈ (MOU) ភ្លាមៗ ជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលបរទេស ហើយធ្វើការនិរទេសបុគ្គលិករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលបានធ្វើសកម្មភាពណាមួយនៅក្នុងប្រទេសកម្ពុជា ដោយមិនមានការចុះបញ្ជី ឬអនុស្សរណៈ។

ជាទីបញ្ចប់ ច្បាប់នេះក៏មានបទប្បញ្ញត្តិដ៏តឹងរ៉ឹងថ្មីៗជាច្រើនទៀត អំពីការធ្វើរបាយការណ៍សកម្មភាពនិងហិរញ្ញវត្ថុ និងមានអំណាចក្នុងការត្រួតពិនិត្យដោយរាជរដ្ឋាភិបាល ក្នុងការធ្វើសវនកម្ម ហើយមានលក្ខខណ្ឌតម្រូវដ៏ច្រើនសន្ធឹកសន្ធាប់ ដែលលក្ខខណ្ឌទាំងនោះតម្រូវឱ្យមានការដាក់ជូននូវព័ត៌មានទាំងអស់ស្តីពីការផ្លាស់ប្តូរអ្នកដឹកនាំ និងការរៀបចំចាត់ចែងហិរញ្ញវត្ថុនិងការទំនាក់ទំនងជាមួយម្ចាស់ជំនួយ។

រាជរដ្ឋាភិបាលបានប្រកាសថា សេចក្តីព្រាងច្បាប់ថ្មីដែលត្រូវបានយល់ព្រមហើយនេះ គឺដូចគ្នាទៅនឹងសេចក្តីព្រាងចុងក្រោយដែលបានបើកចំហជាសាធារណៈ នៅខែធ្នូ ឆ្នាំ ២០១១។ ក៏ប៉ុន្តែដោយការវិភាគលើសេចក្តីព្រាងច្បាប់ថ្មីដែលបានលេចចេញឥឡូវនេះ បានបង្ហាញអំពីការកែប្រែយ៉ាងច្រើន ហើយសេចក្តីព្រាងច្បាប់ដ៏គ្រោះថ្នាក់នេះ គឺនឹងត្រូវបញ្ជូនទៅដល់រដ្ឋសភាជាតិឆាប់ៗនេះ។

សេចក្តីព្រាងច្បាប់នេះរំលោភលើរដ្ឋធម្មនុញ្ញកម្ពុជា និងកាតព្វកិច្ចរបស់កម្ពុជា ដែលនៅក្រោមច្បាប់អន្តរជាតិ។ សេចក្តីព្រាងច្បាប់នេះគឺមិនចាំបាច់ឲ្យមានទេ ហើយត្រូវតែលុបចោល។

ខាងក្រោមនេះគឺជាការវិភាគច្បាស់លាស់ទៅលើបទប្បញ្ញត្តិសំខាន់ៗ នៅក្នុងសេចក្តីព្រាងច្បាប់ថ្មីដែលត្រូវបានឯកភាពរួចហើយ។ ច្បាប់នេះកាន់តែមានភាពធ្ងន់ធ្ងរឡើងៗ បើប្រៀបធៀបជាមួយសេចក្តីព្រាងច្បាប់ខែធ្នូ ឆ្នាំ២០១១ ហើយមានផលប៉ះពាល់ចំពោះក្រុមមនុស្ស ដែលមានប្រតិបត្តិការនៅកម្ពុជា។

### ជំពូកទី ១ - និយមន័យនៃអង្គការមិនមែនរដ្ឋាភិបាល និងសមាគម

- មាត្រា ៤ ថ្វីត្បិតតែមាត្រានេះមិនប៉ះពាល់ដល់អង្គការសហគមន៍មូលដ្ឋានក៏ដោយ ក៏ប៉ុន្តែក្នុងនិយមន័យដ៏ទូលំទូលាយរបស់សមាគម ដែលតម្រូវឱ្យអង្គការទាំងនោះធ្វើការចុះបញ្ជីផងដែរ។ បើមានការតម្រូវឲ្យចុះបញ្ជី ចំពោះក្រុមមូលដ្ឋាន និងអង្គការសហគមន៍មូលដ្ឋាន នេះអាចមានផលប៉ះពាល់ធ្ងន់ធ្ងរលើសេរីភាពនៃការបង្កើតសមាគមរបស់ក្រុមទាំងនោះ។ លើសពីនេះទៅទៀត ការកំណត់និយមន័យមិនច្បាស់លាស់ អាចធ្វើអោយមានការរឹតត្បិតចំពោះការចុះបញ្ជី សម្រាប់ក្រុមជាច្រើនដែលកំពុងធ្វើសកម្មភាពស្របច្បាប់ ឧទាហរណ៍ដូចជា សកម្មជនដីធ្លីជាដើម។

### ជំពូកទី ២ - ការបង្កើតសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងការចុះបញ្ជីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

- មាត្រា ៥ បង្កើតលក្ខខណ្ឌតឹងរ៉ឹងជាងមុន ចំពោះការបង្កើតអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក ដោយតម្រូវឱ្យមានសមាជិកស្ថាបនិកដែលជារូបវន្តបុគ្គលចំនួនយ៉ាងតិច ៥ (ប្រាំ) រូប

ដែលចំនួននេះ មានការកើតឡើងពីចំនួន ៣ (បី) រូប ដែលមាននៅក្នុងសេចក្តីព្រាងច្បាប់លើកទី ៤ (ខែធ្នូ ឆ្នាំ២០១១)។

- មាត្រា ៥ ក៏បានហាមឃាត់បុគ្គលមិនឲ្យបង្កើតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ប្រសិនបើបុគ្គលនោះធ្លាប់បំពេញតួនាទីជាថ្នាក់ដឹកនាំ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីម្តងហើយ ដោយរដ្ឋាភិបាល។ មាត្រានេះបង្ហាញថាច្បាប់នេះអាចនឹងត្រូវយកមកប្រើប្រាស់ដើម្បីប្រឆាំងនឹងរូបវន្តបុគ្គល។ ពាក្យថា "តួនាទីជាថ្នាក់ដឹកនាំ" គឺមិនមានភាពច្បាស់លាស់ ដូច្នេះវាអាចពង្រីកនូវវិសាលភាពដល់វិធានការប្រឆាំងនឹងបុគ្គលិករបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។

- មាត្រា ៨ ត្រូវបានពង្រីក ដោយប្រើភាសាដែលឲ្យមានការសម្រេចចិត្តទូលំទូលាយ ដើម្បីអនុញ្ញាតឱ្យក្រសួងមហាផ្ទៃធ្វើការបដិសេធពាក្យសុំចុះបញ្ជី ដោយផ្អែកថា សកម្មភាពទាំងនោះ "ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណីទំនៀមទំលាប់របស់សង្គមជាតិកម្ពុជា"។ ភាសានេះ គឺបើកចំហដល់ការបកស្រាយដ៏ទូលំទូលាយ និងតាមហេតុផលនយោបាយ ហើយអនុញ្ញាតឱ្យរដ្ឋាភិបាលធ្វើការហាមឃាត់ចំពោះសកម្មភាពណាមួយ តាមរយៈការរារាំងការចុះបញ្ជី។ មិនមានដំណោះស្រាយផ្នែករដ្ឋបាលណាមួយឡើយ មានតែបណ្តឹងឧទ្ធរណ៍ទៅតុលាការតែប៉ុណ្ណោះទេ។

- មាត្រា ៩ ត្រូវបានពង្រីកបន្ថែម ដើម្បីធ្វើការហាមឃាត់ចំពោះសកម្មភាពណា ដែលអនុវត្តដោយសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទាំងអស់ដែលមិនបានចុះបញ្ជី ដូចដែលមានចែងក្នុងមាត្រា ៤។ លក្ខខណ្ឌតម្រូវជាមូលដ្ឋាននេះ គឺមានភាពរឹតបន្តឹងហួសហេតុ និងអាចចាត់ទុកសកម្មភាពរបស់ក្រុមមូលដ្ឋាន និងអង្គការសហគមន៍មូលដ្ឋាន នៅក្នុងលក្ខណៈដូចគ្នាទៅនឹងសកម្មភាពរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ ឥឡូវ ការអនុវត្តសកម្មភាពទាំងអស់នេះ ប្រឈមនឹងការដាក់ពិន័យ នៅក្រោមមាត្រា ៣២ ហើយអនុញ្ញាតឲ្យមានការប្តឹងពីបទល្មើសព្រហ្មទណ្ឌ យោងតាមក្រមព្រហ្មទណ្ឌ។ នៅក្នុងសេចក្តីព្រាងច្បាប់ចាស់ (ខែធ្នូ ឆ្នាំ២០១១) សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលមិនបានចុះបញ្ជី មិនត្រូវបានផ្តល់នូវភាពស្របច្បាប់ក្នុងការធ្វើសកម្មភាព ប៉ុន្តែនៅតែអនុញ្ញាតឱ្យអនុវត្តសកម្មភាពបានដែរ។

- មាត្រា ១១ ផ្តល់នូវអំណាចជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការកំណត់លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើតនិងការចុះបញ្ជីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សម្រាប់នីតិបុគ្គល និងសម្រាប់ជនបរទេស។ នេះមានន័យថា កាតព្វកិច្ចជាក់ស្តែងនៃការចុះបញ្ជី គឺនៅតែមិនទាន់ដឹងច្បាស់លាស់នៅឡើយ។

## ជំពូកទី ៣ - ការចុះបញ្ជីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលបរទេស

- មាត្រា ១២ បង្កើតនូវលក្ខខណ្ឌតម្រូវថ្មីមួយ សម្រាប់គម្រោងរយៈពេលខ្លីរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដោយត្រូវស្នើសុំការអនុញ្ញាតពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ តាមរយៈដៃគូក្នុងស្រុក។ ក្នុងសេចក្តីព្រាងច្បាប់ចាស់ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ គ្រាន់តែតម្រូវឱ្យជូនដំណឹងដល់ក្រសួងនោះតែប៉ុណ្ណោះ។ មិនមានការបញ្ជាក់ច្បាស់លាស់អំពីរយៈពេលនៃគម្រោងរយៈពេលខ្លីឡើយ។

- មាត្រា ១៣ តម្រូវឱ្យសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដាក់បញ្ចូលនូវលិខិតសន្យាផ្តល់នូវរាល់គណនីទាំងអស់ដែលមាននៅក្នុងធនាគារនៅកម្ពុជា។ មាត្រា ១២ ដល់ ១៧ បង្កើតនូវលក្ខខណ្ឌថ្មី សម្រាប់ការយល់ព្រមលើអនុស្សរណៈ។ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលបានចុះអនុស្សរណៈរួចហើយ នឹងត្រូវតម្រូវឱ្យផ្តល់ព័ត៌មានលំអិតអំពីគណនីធនាគារយោងតាមមាត្រា ១៧។

## ជំពូកទី ៥ - កាតព្វកិច្ច អព្យាក្រឹតភាពនយោបាយ និងសវនកម្មហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល

- មាត្រា ២២ លុបចោលនូវកាតព្វកិច្ចក្នុងការជ្រើសរើសបុគ្គលិកជនជាតិខ្មែរឱ្យច្រើនជាអតិបរមា ដូចដែលបានចែងនៅក្នុងសេចក្តីព្រាងច្បាប់លើកទី ៤ (ខែធ្នូ ឆ្នាំ២០១១)។

- មាត្រា ២៤ បញ្ជាក់ដោយមិនបានច្បាស់លាស់ថា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិ និងសមាគមអន្តរជាតិតម្រូវឲ្យមានអព្យាក្រឹតភាពនយោបាយ ដោយមានការគំរាមលុបឈ្មោះចេញពីបញ្ជី។ គួរឱ្យកត់សម្គាល់ផងដែរថា បទប្បញ្ញត្តិនេះមិនត្រូវអនុវត្តចំពោះសមាគមក្នុងស្រុកនោះទេ។ បទប្បញ្ញត្តិនេះអាចត្រូវបានគេអនុវត្តខុស ដើម្បីគាបសង្កត់លើការធ្វើរបាយការណ៍ និងការរិះគន់ណាមួយដោយស្របច្បាប់ចំពោះរាជរដ្ឋាភិបាល ហើយរាជរដ្ឋាភិបាលនឹងធ្វើការឆ្លើយតបទៅនឹងការរិះគន់នេះ តាមរយៈការលុបឈ្មោះចេញពីបញ្ជីជាអចិន្ត្រៃយ៍ចំពោះអង្គការទាំងនោះ ក្រោមការដាក់ទណ្ឌកម្មនៃច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល។

- មាត្រា ២៥ បានបន្ថែមអំណាចក្នុងការជ្រៀតជ្រែកនៅក្នុងប្រតិបត្តិការផ្ទៃក្នុងរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលអាចឈានទៅដល់ការចូលដល់ទីស្នាក់ការ ហើយរឹបអូសកំណត់ត្រានានា។ វាបង្កើតនូវអំណាចទូលំទូលាយបន្ថែមទៀតដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអាជ្ញាធរសវនកម្មជាតិ ដើម្បីធ្វើសវនកម្មលើសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល។ សេចក្តីយោងទាំងឡាយទាក់ទងនឹងលក្ខខណ្ឌជាក់លាក់ដែលនាំឲ្យមានការធ្វើសវនកម្មត្រូវបានលុបចេញ ដែលអនុញ្ញាតឱ្យមានការប្រើប្រាស់បទប្បញ្ញត្តិនេះទៅតាមហេតុផលនយោបាយ។ ក្រសួងមហាផ្ទៃក៏ត្រូវ

បានផ្តល់នូវអំណាច ក្នុងការទាមទារនូវកំណត់ត្រាហិរញ្ញវត្ថុនិងសកម្មភាពរបស់សមាគមក្នុងស្រុក ដោយមិនចាំបាច់មានមូលហេតុ ឬការទទួលខុសត្រូវ។ មាត្រានេះ មិនអនុញ្ញាតឲ្យមានសិទ្ធិប្តឹងជំទាស់នោះទេ ហើយការបដិសេធក្នុងការអនុវត្តតាម នឹងត្រូវទទួលរងការដាក់ទណ្ឌកម្មក្រោមជំពូកទី ៧។ សេចក្តីព្រាងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលមានបំណងធ្វើការដាក់បន្ទុកផ្នែករដ្ឋបាលបន្ថែមទៀត ទៅលើអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក តាមរយៈការតម្រូវឱ្យមានការដាក់តម្កល់ច្បាប់ចម្លងនៃគ្រប់ឯកសារដែលផ្ញើជូនទៅម្ចាស់ជំនួយ ព្រមទាំងសំណើសុំថវិកា និងកិច្ចព្រមព្រៀងហិរញ្ញប្បទានដែលម្ចាស់ជំនួយបានយល់ព្រម ឱ្យបានក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ឬថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម។ លក្ខខណ្ឌនេះអាចដាក់ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល នៅក្រោមការត្រួតពិនិត្យរបស់រាជរដ្ឋាភិបាល។ បទប្បញ្ញត្តិបែបនេះបានបង្ហាញពីចេតនានយោបាយ ក្នុងការរារាំងសមត្ថភាពប្រតិបត្តិការរបស់ក្រុមសង្គមស៊ីវិល និងអាចមានផលប៉ះពាល់ធ្ងន់ធ្ងរ ដល់សមត្ថភាពរបស់ក្រុមមូលដ្ឋាននិងអង្គការសហគមន៍មូលដ្ឋាន ក្នុងការបំពេញតាមលក្ខខណ្ឌនៃការចុះបញ្ជី។

**ជំពូកទី ៦ - តុលាការបានបញ្ជាឱ្យចាត់ចែងធនធាន បន្ទាប់ពីការផ្អាក ការលុបចោល ឬការបញ្ចប់នៃអនុស្សរណៈ**

- មាត្រា ២៩ បានដាក់ទ្រព្យសម្បត្តិនិងធនធានរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកឲ្យប្រឈមនឹងការរឹបអូស។ សមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាមួយ ដែលត្រូវបានរំលាយ ឬលុបឈ្មោះចេញពីបញ្ជីដោយការសម្រេចរបស់តុលាការ ត្រូវតែគោរពតាមសេចក្តីសម្រេចទាំងអស់របស់តុលាការ ដែលទាក់ទងនឹងការគ្រប់គ្រងធនធាននិងទ្រព្យសម្បត្តិរបស់ខ្លួន។ ហានិភ័យចំពោះទ្រព្យសម្បត្តិនេះ ក៏បានដើរតួជាការបង្អាក់លើការប្តឹងជំទាស់នឹងការសម្រេចចិត្តនៃក្រសួងមហាផ្ទៃផងដែរ។

**ជំពូកទី ៧ - ការដាក់ទណ្ឌកម្ម**

- ជំពូកទី ៧ វិធានការរដ្ឋបាល ត្រូវបានពង្រីកពីចំនួនពីរមាត្រាទៅប្រាំពីរមាត្រា ដែលបង្ហាញនូវចេតនារបស់រាជរដ្ឋាភិបាល ក្នុងការប្រើច្បាប់នេះដើម្បីបំបិទសម្លេងរបស់សង្គមស៊ីវិល។ ជំពូកនេះបានលុបចោលការព្រមានពីក្រសួង រហូតដល់ការលុបចោលការចុះបញ្ជី និងបញ្ចប់អនុស្សរណៈ ដោយដាក់នូវលក្ខខណ្ឌតឹងរឹងយ៉ាងខ្លាំងជាងមុនទៅទៀត។

- មាត្រា ៣០ ចែងថា ឥឡូវនេះអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អាចត្រូវបានលុបឈ្មោះចេញពីបញ្ជី ប្រសិនបើអង្គការត្រូវបានរកឃើញថា បានរំលោភលើលក្ខខណ្ឌអព្យាក្រឹតភាពនយោបាយ

ក៏ដូចជាការរំលោភលើកាតព្វកិច្ចក្នុងការផ្តល់របាយការណ៍ហិរញ្ញវត្ថុ។ មាត្រា ៣០ ក៏បានបន្ថែមពាក្យដែលមានន័យទូលំទូលាយនិងមិនច្បាស់លាស់ សម្រាប់ផ្តល់អំណាចសម្រេចចិត្តរបស់រដ្ឋមន្ត្រីក្នុងការលុបឈ្មោះចេញពីបញ្ជី ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា ដែលធ្វើសកម្មភាព និងមានគោលបំណងធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីទំនៀមទំលាប់របស់សង្គមជាតិកម្ពុជា។ រាជរដ្ឋាភិបាលក៏អាចផ្អាកសកម្មភាព ឬលុបឈ្មោះចេញពីបញ្ជីចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា ដែលបំពានលើលក្ខន្តិកៈរបស់ខ្លួនឯងផ្ទាល់។

- មាត្រា ៣២ បញ្ចូលនូវការពិន័យថ្មីដ៏តឹងរ៉ឹងមួយ ចំពោះសកម្មភាពដែលអនុវត្តដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលមិនបានចុះបញ្ជី។ មាត្រានេះសង្កត់ធ្ងន់ថា អាជ្ញាធរពាក់ព័ន្ធ *ត្រូវតែធ្វើសកម្មភាព* ជាបន្ទាន់ ចំពោះសកម្មភាពដែលធ្វើឡើងដោយក្រុមនានារបស់ប្រជាពលរដ្ឋដែលមិនបានចុះបញ្ជី។ នៅក្នុងករណីនៃការបន្តធ្វើសកម្មភាព ក្រសួងមហាផ្ទៃអាចធ្វើការពិន័យលើសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលមិនបានចុះបញ្ជី ចន្លោះពី ៥ លានរៀល រហូតចំនួនអតិបរមា ១០ លានរៀល និងបញ្ជូនករណីនេះទៅកាន់តុលាការដើម្បីផ្តន្ទាទោស។ កម្រិតនៃការពិន័យនេះ គឺមានលក្ខណៈធ្ងន់ធ្ងរពេក សម្រាប់ក្រុមមូលដ្ឋាន និងអង្គការសហគមន៍មូលដ្ឋាន។ របបនៃការដាក់ទណ្ឌកម្មនេះក៏អនុវត្តផងដែរទៅលើសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានបន្តសកម្មភាពរបស់ខ្លួន បន្ទាប់ពីត្រូវបានលុបឈ្មោះចេញពីបញ្ជី។
- មាត្រា ៣៣ ធ្វើវិសោធនកម្មលើការដាក់ទណ្ឌកម្ម សម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដោយនឹងមានការជូនដំណឹងជាដំបូងមួយរបស់ក្រសួង ដែលមានរយៈពេល ៣០ថ្ងៃ ហើយឥឡូវនេះ បន្តដោយផ្ទាល់ដោយការបញ្ចប់អនុស្សរណៈនៃការយោគយល់តែម្តង។ មូលហេតុនៃការបញ្ចប់អនុស្សរណៈ រួមមាន ការបន្តមិនគោរពតាមបទប្បញ្ញត្តិនានាស្តីពីរបាយការណ៍ហិរញ្ញវត្ថុនៃមាត្រា ១៧ និង ២៥ និងលក្ខខណ្ឌអព្យាក្រឹតភាពនយោបាយ នៃមាត្រា ២៤។
- មាត្រា ៣៤ បញ្ជាក់ថា អាជ្ញាធរពាក់ព័ន្ធនានាត្រូវតែចាត់វិធានការលើអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមបរទេសដែលប្រតិបត្តិការដោយគ្មានការចុះបញ្ជី ឬបន្តដំណើរការបន្ទាប់ពីមានការបញ្ចប់អនុស្សរណៈនៃការយោគយល់។ ជនបរទេសនានាដែលបំរើការងារឱ្យអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមបរទេសដែលមិនបានចុះបញ្ជី អាចនឹងត្រូវបាននិរទេស និង/ឬ ទទួលរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌបន្ថែមទៀតផងដែរ។ មាត្រានេះ បង្កឱ្យមានហានិភ័យជាពិសេសមួយ ដល់បុគ្គលិកជាជនបរទេសរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលធ្វើការងារផ្នែកស៊ើបអង្កេតនៅ

ក្នុងប្រទេសកម្ពុជា ដោយនឹងត្រូវស្ថិតនៅក្រោមការបន្តគំរាមកំហែងនៃការនិរទេសជាបន្ទាន់ ប្រសិនបើអង្គការរបស់ពួកគេត្រូវបានលុបឈ្មោះចេញពីបញ្ជី។

- មាត្រា ៣៥ បានបង្កើតហេតុផលយ៉ាងទូលំទូលាយបន្ថែមទៀតសម្រាប់ការបញ្ចប់អនុស្សរណៈនៃការយោគយល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសមាគមអន្តរជាតិ ដែលរួមមាន "សកម្មភាពដែលធ្វើឱ្យប៉ះពាល់ដល់សន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីទំនៀមទំលាប់នៃសង្គមជាតិកម្ពុជា"។ មាត្រានេះក៏បានទុកឱកាសក្នុងការផ្តន្ទាទោសព្រហ្មទណ្ឌបន្ថែមទៀតផងដែរ។ មាត្រានេះមិនមានតម្រូវការនៃការជូនដំណឹង ឬការផ្តល់ឲ្យប្តឹងទាស់ ឬដំណោះស្រាយសម្រាប់ការបញ្ចប់អនុស្សរណៈនោះទេ។

- មាត្រា ៣៦ បានបន្ថែមការលើកឡើងដែលមិនចាំបាច់អំពីលទ្ធភាពសម្រាប់ការផ្តន្ទាទោសបទល្មើសព្រហ្មទណ្ឌបន្ថែមទៀត ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលធ្វើសកម្មភាពប៉ះពាល់ដល់សន្តិភាព ដូចជាសកម្មភាពពាក់ព័ន្ធនឹងការលាងលុយកខ្វក់ ការផ្គត់ផ្គង់ហិរញ្ញវត្ថុដល់ភេរវកម្ម ឬសកម្មភាពខុសច្បាប់ផ្សេងៗទៀត។

## ជំពូកទី ៨ - ការចុះបញ្ជីឡើងវិញ សម្រាប់អង្គការដែលមានស្រាប់

- មាត្រា ៣៧ បានលុបចេញនូវកាតព្វកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុកណាដែលបានតម្កល់សុំណុំលិខិតរួចហើយ ក្នុងការជូនដំណឹងដល់ក្រសួងមហាផ្ទៃ ក្នុងរយៈពេល ៣៦៥ ថ្ងៃ គិតចាប់ពីថ្ងៃនៃការចូលជាធរមាននៃច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល (LANGO) អំពីការបន្តសកម្មភាពរបស់អង្គការ ដោយត្រូវចាត់ទុកថាអង្គការនោះបានចុះបញ្ជី។

- មាត្រា ៣៨ អនុញ្ញាតឱ្យមានការចុះបញ្ជីដោយស្វ័យប្រវត្តិចំពោះអង្គការមិនមែនរដ្ឋាភិបាល និងសមាគមអន្តរជាតិណា ដែលបានចុះអនុស្សរណៈនៃការយោគយល់ជាមួយរដ្ឋាភិបាលរួចហើយ ហើយការចុះបញ្ជីមានសុពលភាពរហូតដល់ថ្ងៃកំណត់អនុស្សរណៈដែលបានចុះរួច។